លេខៈ ធ៧-០០-៤៦ ប្រក

# ប្រកាស

## ស្តីពី

## អនុបាតសាធនភាពរបស់ធនាគារ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## ស ំ រេ ច

**ប្រការ ១ ._**

ធនាគារទាំងអស់ត្រូវពិនិត្យជាអចិន្ត្រៃយ៍ នូវអនុបាតសាធនភាពរបស់ខ្លួនអោយបានស្របតាមបញ្ញត្តិនៃប្រកាសនេះ ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យឥណទានសរុប មិនត្រូវតិចជាងម្ភៃភាគរយ (២០%) ឡើយ ។

**ប្រការ ២ ៈ**

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៣ ៈ**

**៣ៈ១ៈ** ភាគបែងនៃអនុបាត គឺជាតំលៃទ្រព្យសកម្មសរុប (តំលៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធននិងការរំលោះតំលៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកំរិតហានិភ័យឥណទាន ។ ភាគបែងនេះមិនរាប់បញ្ចូលនូវខ្ទង់ដែលបានដកចេញ នៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**៣ៈ២ៈ** ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម ÷

**៣ៈ២.១ៈ** ការថ្លឹងសូន្យភាគរយ (zero weighting) ចំពោះ ÷

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលបានធានាដោយប្រាក់បញ្ញើនៅធនាគារដទៃ
- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ( Claims on sovereigns ) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor 's Corporation ។

**៣ៈ២.២ៈ** ការថ្លឹង ២0% ចំពោះ ÷

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor 's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor 's Corporation ។

**៣.២.៣.** ការថ្លឹង ៥០% ចំពោះ ÷

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- តាមវិធីសាស្ត្ររបស់ Standard and Poor 's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor 's Corporation ។

**៣.២.៤.** ការថ្លឹង ១០០% ចំពោះ

- ទ្រព្យសកម្មដទៃទៀតទាំងអស់ ។

**៣.៣.** បញ្ញត្តិដូចតទៅនេះ នឹងត្រូវអនុវត្តចំពោះខ្ទង់ក្រៅតារាងតុល្យការ ÷

**៣.៣.១.** ខ្ទង់ក្រៅតារាងតុល្យការត្រូវបានចាត់ថ្នាក់ជា ៤ ប្រភេទ ស្របតាមតារាងដែលមានក្នុងឧបសម្ព័ន្ធ ។ ខ្ទង់ក្រៅតារាងតុល្យការទាំងនេះត្រូវបានយកមកគិត ÷

- តាមតំលៃទាំងស្រុងរបស់វា នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង
- តាមតំលៃ ៥០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យកំរិតមធ្យម
- តាមតំលៃ ២០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យធូនល្មម ( moderate risk)
- ខ្ទង់ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាបមិនត្រូវបានយកមកគិតទេ ។

**៣.៣.២.** ចំនួនប្រាក់ដែលបានកំណត់ខាងលើត្រូវគុណជាមួយនឹងប្រភេទថ្លឹងដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៣-២ ដែលត្រូវអនុវត្តចំពោះប្រភេទនៃការថ្លឹងរបស់អត្ថគាហកៈ ឬប្រភេទទ្រព្យសកម្មពាក់ព័ន្ធនោះ ។ ប៉ុន្តែ ÷

- ក្នុងករណីនៃការសន្យាដែលមានការធានាពីតតិយជន ការថ្លឹងគឺជាការថ្លឹងដែលអនុវត្តចំពោះអ្នកធានា ឬចំពោះអ្នកដែលត្រូវបានគេធានា

- ក្នុងករណីនៃការធានាចំពោះធនាគារមួយផ្សេងទៀតទាក់ទងដល់ការសងបំណុលដែលរក្សាទុកនៅធនាគារផ្សេងទៀតនោះ  ការថ្លឹងជាការថ្លឹងដែលអនុវត្តចំពោះឥណទេយ្យទាំងនេះ ។

## ប្រការ ៤.-

ធនាគារត្រូវប្រតិវេទអនុបាតសាធនភាពរបស់ខ្លួននៅ ថ្ងៃទី ៣០ ខែ មិថុនា និង ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងអាចតំរូវអោយធនាគារណាមួយគណនាអនុបាតសាធនភាពរបស់ខ្លួន នៅកាលបរិច្ឆេទផ្សេងទៀត ស្របតាមការចាំបាច់នៃការត្រួតពិនិត្យ ។

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ក្នុងសារាចរ ពីគំរូសំរាប់គណនាអនុបាត ដោយត្រូវប្រកាសពីខ្ទង់ទាំងឡាយក្នុងគំរូនេះ ។

ប្រសិនបើចាំបាច់  ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ច្បាស់អំពីលក្ខណៈពិសេសរបស់ខ្ទង់ដែលត្រូវអនុវត្តការថ្លឹង ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ។

ធនាគារជាតិនៃកម្ពុជាអាចបដិសេធចំពោះការថ្លឹងដែលកំពុងអនុវត្តចំពោះទ្រព្យសកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ  ប្រសិនបើគិតថាខ្ទង់នោះមិនអាចបំពេញតាមល័ក្ខខ័ណ្ឌជាធរមានបានដោយពេញចិត្តនោះទេ ។

## ប្រការ ៥.-

ធនាគារជាតិនៃកម្ពុជាតំរូវអោយមានការយកចិត្តទុកដាក់ថា  គោលនយោបាយគណនេយ្យខ្សោយ ឬ មិនគ្រប់គ្រាន់ធ្វើឱ្យអន្តរាយដល់សារៈប្រយោជន៍នៃកិរិតដើមទុន ដោយបង្កឱ្យមានអនុបាតសាធនភាពមិនត្រឹមត្រូវ ឬមិនអាចជឿបាន ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកថា ការអនុវត្តន៍គណនេយ្យរឹងមាំ និងការវាយតំលៃត្រឹមត្រូវជាការសំខាន់ ជាពិសេសចំពោះការចាត់ថ្នាក់ត្រឹមត្រូវនិងការធ្វើសំវិធានធនទ្រព្យសកម្មតាមបញ្ញត្តិនៃប្រកាសស្តីពីចំណាត់ថ្នាក់និងការធ្វើសំវិធានធនលើបំណុលអាក្រក់  និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ។

**ប្រការ ៦.~**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

# Rbkar 7ç~

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

# Rbkar 8ç~

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៧
  " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពិតមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

## ឧបសម្ព័ន្ធនៃប្រកាសស្ដីពីអនុបាតសាធនភាពរបស់ធនាគារ

### ចំណាត់ថ្នាក់ខ្ពង់ក្រៅតារាងតុល្យការ ដែលមានចែង

### ក្នុងកថាខ័ណ្ឌ ៣-៣.១

ប្រតិបត្តិការទាំងឡាយណាដែលមិនមានចែងក្នុងតារាងខាងក្រោមនេះ ធនាគារត្រូវចាត់ថ្នាក់ខ្ពង់ទាំងនេះ ក្នុងប្រភេទប្រតិបត្តិការ ដែលមានលក្ខណៈស្រដៀងគ្នា បន្ទាប់ពីបានស្នើសុំធនាគារជាតិនៃកម្ពុជា ប្រសិនបើចាំបាច់ ។

១- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង

- ការធានាលើឥណទាន (ដកចេញហានិភ័យចំពោះអត្ថគាហកៈ)
- ការទទួលព្រម ( acceptance )
- រូបិយបដិភោគ (endorsement) លើផលប័ត្រដែលមិនមានឈ្មោះរបស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុមួយផ្សេងទៀត
- សកម្មភាពប្រតិបត្តិការដោយមានឧបាស្រ័យ ( recourse )
- កំរិតឥណទានមិនអាចបដិសេធបាន (irrevocable credit line) ឬការធានា ដែលមានលក្ខណៈជំនួសឥណទាន ។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យខ្ពស់

២- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម

- ការសន្យាសងប្រាក់តាមឯកសារឥណទាន ដែលបានចេញផ្សាយឬបញ្ជាក់ហើយ នៅពេលដែលទំនិញមិនត្រូវបានប្រើជាវត្ថុបញ្ចាំ
- ការធានានិងសញ្ញាប័ណ្ណឧបត្ថម្ភ ( warranties and indemnity bonds) (រួមទាំង tender , performance, customs and tax bonds ) និងការធានាដែលមិនមានលក្ខណៈជំនួសឥណទាន

- កិច្ចសន្យាផ្តល់ឥណទានមិនទាន់ប្រើ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាអោយខ្ចីដែលមានកាលកំណត់លើសពីមួយឆ្នាំ
- ប្រតិបត្តិផ្សេងទៀតដែលមានហានិភ័យមធ្យម

៣- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យធួនល្មម

- ឯកសារឥណទានដែលត្រូវបានចេញផ្សាយឬបញ្ជាក់ហើយ ទំនិញត្រូវបានប្រើជាវត្ថុបញ្ចាំនិងប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀត
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យធួនល្មម

៤- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាប

- ឥណទានមិនទាន់ប្រើប្រាស់ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាអោយខ្ចីដែលមានកាលកំណត់រហូតពេញមួយឆ្នាំ ឬដែលអាចលុបចោលដោយគ្មានលក្ខខ័ណ្ឌនៅពេលណាក៏បានដោយគ្មានការជូនដំណឹង ។
- ប្រតិបតិការផ្សេងទៀតដែលមានហានិភ័យទាប ។